**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

DBD ENGINEERING

# សេចក្តីប្រកាសព័ត៌មាន

**ស្តីពី**

## សេចក្តីប្រកាសព័ត៌មានស្តីពីការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសដែលរៀបចំដោយក្រុមហ៊ុន នៅក្នុងរបាយការណ៍ប្រចាំត្រីមាស របស់ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក

ក្រុមហ៊ុន **ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក** ("ក្រុមហ៊ុន ឌី ប៊ី ឌី") ជាក្រុមហ៊ុនដំបូងបង្អស់ដែលបានចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិនៅលើទីផ្សារកំណើននៃ ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនដល់វិនិយោគិន និងសាធារណជនទាំងអស់ឲ្យបានជ្រាបថា ក្រុមហ៊ុន ឌី ប៊ី ឌី នឹងផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសដែលរៀបចំដោយក្រុមហ៊ុន ឌី ប៊ី ឌី នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ជូននិយ័តករមូលបត្រកម្ពុជា (ន.ម.ក) ក្នុងរយៈពេល ១ឆ្នាំ គិតចាប់ពីត្រីមាសទី៣ នៃឆ្នាំ២០២១ ដល់ត្រីមាសទី២ នៃឆ្នាំ២០២២។ បន្ថែមពីនេះ ក្រុមហ៊ុន ឌី ប៊ី ឌី នឹងផ្តល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆមាស ដែលត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ យោងតាមលិខិតរបស់ ន.ម.ក លេខ ៥៦០/២១ ន.ម.ក ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២១ ឆ្លើយតបលើសំណើសុំអនុគ្រោះក្នុងការលើកលែងរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាសដោយត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ បន្ទាប់ពីការចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិលើកដំបូងនៅផ្សារមូលបត្រកម្ពុជារបស់ក្រុមហ៊ុន ឌី ប៊ី ឌី ដោយមូលហេតុថា ក្រុមហ៊ុន ឌី ប៊ី ឌី បានព្យាយាមរៀបចំខ្លួន ដើម្បីបំពេញកាតព្វកិច្ចនៅពេលដែលមូលបត្រកម្មសិទ្ធិរបស់ក្រុមហ៊ុនត្រូវបានចុះបញ្ជីលក់នៅផ្សារមូលបត្រកម្ពុជា ឲ្យស្របតាមប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ក៏ប៉ុន្តែក្រុមហ៊ុន ឌី ប៊ី ឌី ត្រូវការពេលវេលាបន្ថែមទៀតក្នុងការរៀបចំការបង្ហាញព័ត៌មានសាជីវកម្មនេះ ឲ្យបានគ្រប់ជ្រុងជ្រោយ សម្រាប់ធានាឲ្យបាននូវប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដើម្បីការពារផលប្រយោជន៍របស់វិនិយោគិន។

សូមវិនិយោគិន និងសាធារណជនទាំងអស់មេត្តាជ្រាប។

រាជធានីភ្នំពេញ ថ្ងៃ ១១កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ត្រូវនឹងថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១

**ក្រុមហ៊ុន ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក**

ព្រះរាជាណាចក្រកម្ពុជា
ក្រុមហ៊ុន
ឌី ប៊ី ឌី អ៊ិនជីនារីង ម.ក
DBD ENGINEERING
Plc.
KINGDOM OF CAMBODIA



DBD Engineering Plc. #68, St.598, SK. Phnom Penh Thmey, K. Sensok, Phnom Penh, CAMBODIA
Tel: (855)78 700 598, E-mail: services@dbdengineering.com, www.dbdengineering.com